ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៩១៥
ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣
-សាលក្រមព្រហ្មទណ្ឌលេខ៖ ១៥ "ញ"
ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ២ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៩១៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted]**រ៉ា ហៅ តូច** ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៦) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ **ធឿន** (រស់) ម្តាយឈ្មោះ [redacted] **ចិន** (រស់) នៅលីវ ជាអនីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៦ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ (ឃុំខ្លួនថ្ងៃទី០៦-០៩-២០២៣)

ជាប់ចោទពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិព្រៃញីក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបើកឡាន មានទីលំនៅស្ថិតនៅភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-បានឃើញ ពាក្យបណ្តឹងចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ពៅ ។

-បានឃើញ របាយការណ៍សរុបលេខះ ១២៦/២០២៣ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ របស់កងរាជអាវុធហត្ថខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខះ ៩០៦ ដ.ស.៣/២៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខះ ៨១៣/២០២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខះ ៤៥ ដចត/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ:**

កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ១៩ និង ១៥នាទី នៅចំណុចភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ មានករណីធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសបង្កឡើងដោយជនត្រូវចោទចំនួន ០៦នាក់ ទី១.ឈ្មោះ [redacted] វិន ភេទប្រុស អាយុ១៨ឆ្នាំ, ទី២.ឈ្មោះ [redacted] ហួតឡៃ ហៅ តើន ភេទប្រុស អាយុ១៩ឆ្នាំ, ទី៣.ឈ្មោះ [redacted] រ៉ា ហៅ តូច ភេទប្រុស អាយុ១៧ឆ្នាំ, ទី៤.ឈ្មោះ [redacted] កែវ ភេទប្រុស អាយុ១៩ឆ្នាំ, ទី៥.ឈ្មោះ [redacted] សំនិត ហៅ ណាត ភេទប្រុស អាយុ២០ឆ្នាំ, និងទី៦.ឈ្មោះ [redacted] ហួតឡុង ភេទប្រុស អាយុ២០ឆ្នាំ បានធ្វើសកម្មភាពគប់កញ្ចក់រថយន្តរបស់ជនរងគ្រោះឈ្មោះ [redacted] ពៅ បណ្តាលឱ្យខូចខាត។ ក្រោយកើតហេតុសមត្ថកិច្ចបានធ្វើការស្រាវជ្រាវឃាត់ខ្លួនជនត្រូវចោទ រួចកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

**នាពេលសវនាការ**

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច បានឆ្លើយថា៖ ចំពោះរឿងហេតុដែលចោទប្រកាន់នេះ គឺខ្ញុំបាទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់នេះប្រាកដមែន ហើយការគប់នេះគឺខ្ញុំពុំមានចេតនាអ្វីនោះទេ ដោយគប់ចោលលេងប៉ុណ្ណោះក៏ប៉ុន្តែបែរជាគប់ត្រូវកញ្ចក់ឡានរបស់គេតែម្តង ដោយខ្ញុំមិនមានចេតនាគប់ប្លន់សម្ភារៈពីអ្នកដទៃនោះទេ។ ដោយកាលពីមុនពេលមានរឿងហេតុនេះនៅវេលាម៉ោងប្រហែល៦ ទៅ ៧យប់ ខ្ញុំបាទមានគ្នាបីនាក់ជិះម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៨ កាំបន្ទះដែលជារបស់មិត្តភក្តិខ្ញុំឈ្មោះ អាតៀ និងទីពីរខ្ញុំមិនស្គាល់ឈ្មោះទេ ហើយរូបខ្ញុំជាអ្នកជិះកណ្តាល ចំណែកឈ្មោះ អាតៀ ជាអ្នកឌុប និងម្នាក់ទៀតជិះខាងក្រោយ។ នៅពេលធ្វើសកម្មភាពគប់ដោយដុំថ្មនោះ គឺខ្ញុំមិនមានចេតនាគប់កញ្ចក់ឡានរបស់គេនោះទេ បែជាក្រោយមកបានគប់ចំឡានរបស់គេតែម្តង។ ក្រោយធ្វើសកម្មភាពគប់កញ្ចក់ឡានគេរួច

ឈ្មោះ អាតឿ និងម្នាក់ទៀតដឹកខ្ញុំទៅផ្ទះ ហើយពួកវាទៅណាទៀតខ្ញុំពុំបានដឹងនោះទេ។ ហើយនៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ពៅ** បានឆ្លើយថា៖ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ខ្ញុំបាទបានដឹកអីវ៉ាន់គេនៅភ្នំដិន ស្ថិតនៅខេត្តតាកែវ ដោយធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ៣ ឆ្ពោះទៅរាជធានីភ្នំពេញវិញ ពេលជិះមកដល់ចំណុចគីឡូម៉ែត្រ៥៣ ស្ថិតនៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ស្រាប់តែមានជនសង្ស័យមួយក្រុមជិះម៉ូតូចំនួន០២គ្រឿងមានគ្នាចំនួន ០៤នាក់បានជិះម៉ូតូបញ្ច្រាស់ទិសគ្នាជាមួយរថយន្តរបស់ខ្ញុំបាទពីទិសខាងត្បូងទៅទិសខាងជើង ហើយក្រុមបក្ខពួកនោះបានធ្វើសកម្មភាពយកដុំថ្មគប់សំដៅមកលើឡានរបស់ខ្ញុំបាទអំឡុងពេលដែលខ្ញុំកំពុងតែបើកឡាន ត្រូវកញ្ចក់ឡានចំកន្លែងខ្ញុំអង្គុយបណ្តាលឱ្យបែកកញ្ចក់ខាងមុខផ្លុះចូលក្នុងរថយន្តត្រូវមុខខ្ញុំត្រង់ចំណុចចំសៀតផ្កាខាងឆ្វេងបែកហូរឈាមយ៉ាងច្រើន ចំណែកឯក្រុមជនល្មើសនោះបានជិះម៉ូតូគេចខ្លួនបាត់។ បន្ទាប់មកមានប្រជាពលរដ្ឋនៅទីនោះដឹកខ្ញុំទៅមន្ទីរពេទ្យឯកជនតែម្តង។ សម្រាប់ការព្យាបាលស្នាមរបួសរហូតមកដល់ពេលនេះអស់ប្រហែលជា១,៦០០$ (មួយពាន់ប្រាំមួយរយដុល្លារអាមេរិក)។ នៅក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងជំងឺចិត្ត និងការខូចខាតសរុបចំនួន ២០,០០០,០០០ (ម្ភៃលានរៀល) និងសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **សំនិត** ហៅ **ណាត** បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនបានទៅកាប់ដូងឱ្យគេនៅខេត្តកំពង់ស្ពឺ ខ្លួនមិនបានធ្វើសកម្មភាពគប់ដុំថ្មទៅលើរថយន្តគេជាមួយឈ្មោះ [redacted]វ៉ា នៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុក សំរោង ខេត្តតាកែវ នោះទេ ហើយខ្លួនក៏មិនបានដឹងរឿងគប់កញ្ចក់គេនោះទេ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] វ៉ា (មិនសូវស្និទ្ធទេ) និងធ្លាប់ដើរលេងជាមួយវាបានចំនួនម្តងអំឡុងឆ្នាំ២០២២ គឺទៅលេងបាល់ទាត់នៅសាលាអង្គជុំក្នុងទីធ្លាវត្តអង្គជុំ ក្រោយមកខ្លួនមិនដែលដើរជាមួយឈ្មោះ [redacted] វ៉ា ទៀតនោះទេ។ ខ្លួនមិនស្គាល់បក្ខពួករបស់ឈ្មោះ [redacted] វ៉ា នោះទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនកំពុងតែចុចទូរស័ព្ទនៅផ្ទះសមត្ថកិច្ចមិនបានដកហូតអ្វីពីរូបខ្លួននោះទេ។ ខ្លួនសំណូមពរសុំដល់លោកតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **វីន** បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់ របស់តំណាងអយ្យការនោះទេ។ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនទៅធ្វើការរោងចក្រធម្មតា ហើយមកពីធ្វើការខ្លួនមកផ្ទះលេងបាល់ទះលេងបាល់រួច ខ្លួនបានទៅលេងផ្ទះបងប្រុសជីដូនមួយទៅលេងជាមួយក្មួយអាយុប្រហែលមួយខួបជាងនៅជាប់របងផ្ទះរបស់ខ្លួននៅភូមិដំណាក់ត្រាច ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ នៅពេលនោះនៅផ្ទះបងរបស់ខ្លួនមានគ្នា៥នាក់ ទីមួយឈ្មោះ ជា ភេទប្រុស អាយុ៣០ឆ្នាំ ទីពីរ ឈ្មោះ [redacted] បឿន ភេទស្រី ទីបីឈ្មោះ [redacted] ទីបួនឈ្មោះ វេក ភេទប្រុស និងរូបខ្លួន រហូតដល់ម៉ោង៧យប់ ទើបខ្លួនមកផ្ទះហើយខ្លួនមិន



Scanned with CamScanner

បានទៅណានោះទេ ខ្លួននៅផ្ទះជាមួយឪពុកម្ដាយបងប្អូនខ្លួនហូបបាយហើយក៏ចូលគេង។ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនបានឧបយាយទៅវត្ត ហើយត្រឡប់មកពីវត្តវិញក៏ជួបឈ្មោះ [redacted] ហួតឡៃ ហៅ តើន ទៅផឹកស្រ្វឹងក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្ដងពាក់ព័ន្ធនឹងការគប់កញ្ចក់ឡាន ខ្លួនសូមបញ្ជាក់ថា ខ្លួនមិនធ្លាប់ធ្វើសកម្មភាពគប់កញ្ចក់ឡានគេនោះទេ ចំណែកឈ្មោះ [redacted] រ៉ា ខ្លួនធ្លាប់ស្គាល់ពេលធ្វើការរោងចក្រជាមួយគ្នា ប៉ុន្តែខ្លួនមិនធ្លាប់បានដើរជាមួយឈ្មោះ [redacted] រ៉ានោះទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន ហើយបានដកហូតម៉ូតូចំនួន០១គ្រឿង ម៉ាក Honda Dream ពណ៌ខ្មៅពាក់ស្លាកលេខ តាកែវ 1JD-5543 លេខតួ ND125M-6179523 ពីខ្លួនដែលម៉ូតូនេះជារបស់ឪពុកខ្លួន ។ ខ្លួនសំណូមពរសុំដល់លោកតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **ហួតឡុង** បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួននៅផ្ទះ និងបានទៅលេងបាល់នៅក្បែរផ្ទះមិនបានទៅណាទៀតនោះទេ។ ខ្លួនមិនបានធ្វើសកម្មភាពគប់ដុំថ្មទៅលើរថយន្តគេជាមួយឈ្មោះ [redacted] រ៉ា នៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវនោះទេ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] រ៉ា (មិនសូវស្និទ្ធទេ) និងធ្លាប់ដើរលេងជាមួយវាចំនួនម្ដងអំឡុងឆ្នាំ២០២២ គឺទៅដើរលេងនៅវត្ត ហើយនោះអំឡុងខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនធ្លាប់ទៅខារ៉ាអូខេជាមួយឈ្មោះ [redacted] រ៉ា ប៉ុន្តែមិនមានបញ្ហា ក្រោយមកខ្ញុំបាទមិនដែលដើរជាមួយឈ្មោះ សុខ រ៉ា ទៀតនោះទេ។ ខ្លួនមិនស្គាល់បក្ខពួករបស់ឈ្មោះ សុខ រ៉ា នោះទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន សមត្ថកិច្ចមិនបានដកហូតអ្វីពីរូបខ្លួននោះទេ។ ខ្លួនសំណូមពរសុំដល់លោកតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ***កែវ*** បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់ របស់តំណាងអយ្យការនោះទេ។ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនចេញពីធ្វើការម៉ោង៤រសៀល ហើយដល់ម៉ោង៥ជាងខ្លួនទៅឧបម៉ែចេញពីកន្លែងធ្វើការរបស់គាត់ (អ្នកសំអាតផ្ទះសំណាក់) ហើយមិនបានចេញក្រៅនោះទេ។ ខ្លួនមិនបានធ្វើសកម្មភាពគប់ដុំថ្មទៅលើរថយន្តគេជាមួយឈ្មោះ [redacted] រ៉ា នៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវនោះទេ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] រ៉ា (មិនសូវស្និទ្ធទេ) និងធ្លាប់ដើរលេងជាមួយវាចំនួនពីរដងអំឡុងឆ្នាំ២០២២ គឺទៅដើរលេងនៅវត្តក្រោយមកខ្លួនមិនដែលដើរជាមួយឈ្មោះ សុខ រ៉ា ទៀតនោះទេ។ ខ្លួនស្គាល់បក្ខពួករបស់ឈ្មោះ [redacted] រ៉ា ដែលដើរលេងជិតស្និទ្ធជាមួយវាមានឈ្មោះ [redacted] ឈ្មោះ ចុនា ឈ្មោះ វិន ឈ្មោះ វុិត ឈ្មោះ ប៉ុន ឈ្មោះ យុទ្ធ ឈ្មោះ អុី ឈ្មោះ សុខរ៉ា ឈ្មោះ ណា និងឈ្មោះ សិដ្ឋ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣ ហើយសមត្ថកិច្ចបានដកហូតម៉ូតូចំនួន០១គ្រឿង ម៉ាកហុង ដាសេ១២៥ ពណ៌ខ្មៅ ស្លាកលេខ តាកែវ 1D-3266 និងទូរស័ព្ទដៃ ចំនួន០១គ្រឿងម៉ាក VIVO។ ខ្លួនសំណូមពរសុំដល់លោកតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូប ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។



Scanned with CamScanner

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ហួតឡៃ **ហៅ តើន** បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនមិនបានចេញទៅណានោះទេ ព្រោះគ្មានអីជិះខ្លួននៅផ្ទះមើលក្មួយនៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ខ្លួនសូមបញ្ជាក់ថា កន្លងមកខ្លួនមិនដែលធ្វើសកម្មភាពគប់កញ្ចក់ឡានរបស់គេនោះទេ ចំណែកឈ្មោះ [redacted] រ៉ា ត្រូវជាមិត្តភក្តិមិនសូវស្និទ្ធទេ ខ្លួនធ្លាប់ដើរជាមួយឈ្មោះ [redacted] រ៉ា បានម្តងគឺដើរលេងបុណ្យអុំទូកកាលពីឆ្នាំ២០២២ ក្រៅពីនេះ ខ្លួនមិនដែលដើរជាមួយវាទៀតទេ។ ទាក់ទងនឹងរឿងគប់កញ្ចក់ឡានគេនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ នោះខ្លួនមិនដឹងនោះទេ។ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនដើរចេញពីផ្ទះក៏ជួបឈ្មោះ [redacted] វីន ឈ្មោះ [redacted] វីន ក៏ឌុបខ្លួនទៅផឹកស្រ្ទីងនៅផ្សារប៉ាង្គីសីក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តងពាក់ព័ន្ធនឹងការគប់កញ្ចក់ឡាន។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន សមត្ថកិច្ចមិនបានដកហូតអ្វីពីរូបខ្លួនទេ។ ខ្លួនសំណូមពរសុំដល់លោកតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** បានធ្វើសេចក្តីកត់សម្គាល់ខ្លីៗថា៖ នៅថ្ងៃកើតហេតុខ្ញុំបាទពុំមានចេតនាគប់កញ្ចក់ឡានរបស់គេដើម្បីប្លន់យកអ្វីនោះទេ គឺគប់កាប់សាញតែប៉ុណ្ណោះ និងមិនចង់គប់ចំឡានរបស់គេនោះដែរ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានសួរដេញដោល និងស្តាប់ចម្លើយរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿង គឺតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ដោយសុំឱ្យផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ដដែល និងសុំដល់តុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទនេះតាមច្បាប់។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា៖ ឆ្លងតាមការសួរដេញដោលនៅក្នុងអង្គសវនាការនេះឃើញថាកូនក្តីខ្ញុំឈ្មោះ [redacted] **រ៉ា ហៅ តូច** បានឆ្លើយសារភាពថា៖ ចំពោះរឿងហេតុនេះ គឺខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ដោយបានយកដុំថ្មគប់ទៅលើកញ្ចក់ឡានរបស់គេពិតមែន ហើយការគប់នេះ គឺមិនមានចេតនាក្នុងការគប់ប្លន់យកទ្រព្យសម្បត្តិរបស់គេនោះទេ ម្យ៉ាងទៀតឃើញថាកូនក្តីខ្ញុំបាទបានឆ្លើយនៅពេលនេះ គឺបានសារភាពគ្រប់បែបយ៉ាង និងពុំបង្កការស្មុគស្មាញដល់តុលាការនោះទេ។ ហេតុដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** គឺសូមស្នើសុំដល់តុលាការសម្រេចពិចារណាក្នុងការផ្តន្ទាទោសលើកូនក្តីខ្ញុំបាទ និងមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង និងចំពោះការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺខ្ញុំសូមស្នើសុំដល់តុលាការមេត្តាពិចារណាត្រង់ចំណុចនេះ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថាឃើញថានៅក្នុងអង្គសវនាការនេះកូនក្តីខ្ញុំបាទបានឆ្លើយសារភាព



Scanned with CamScanner

នូវកំហុសរបស់ខ្លួនហើយ ដោយគាត់មានការភ្ញាក់រឭក និងសហការក្នុងការផ្តល់ចម្លើយជូនតុលាការទៀតផង ព្រមទាំងមានការសោកស្តាយចំពោះអំពើដែលបានប្រព្រឹត្តផង ហើយគាត់ក៏ពុំមានចេតនាក្នុងការគប់ប្លន់យកទ្រព្យសម្បត្តិរបស់គេនោះដែរ។ ហេតុនេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសូមស្នើសុំដល់តុលាការមេត្តាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច ថា៖ ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោស និងសម្រាលទោសដល់រូបខ្ញុំផង ព្រោះខ្ញុំបានដឹងពីកំហុសហើយ និងសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ប្រព្រឹត្តអំពើនេះបន្តទៀតហើយ និងធ្វើជាពលរដ្ឋល្អនៅក្នុងសង្គម។

-**ក្រោយពីបាន** ស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី។

-**ក្រោយពីបាន** ស្តាប់អំណានចម្លើយបំភ្លឺរបស់សាក្សី ។

-**ក្រោយពីបាន** ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង។

-**ក្រោយពីបាន** ស្តាប់សេចក្តីកត់សម្គាល់ខ្លីៗរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-**ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ពិភាក្សាសម្ងាត់ជាមួយនឹងក្រុមប្រឹក្សាជំនុំជម្រះរួចហើយ។

-**ក្រោយពីបាន** ពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខ៖ ៨១៣/២០២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ ដោយបានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] រ៉ា ហៅ តូច ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៦) មកជំនុំជម្រះពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច អំណានចម្លើយបំភ្លឺរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី និងអំណានចម្លើយបំភ្លឺរបស់សាក្សី ក៏ដូចជាតាមរបាយការណ៍នានារបស់សមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកសំរោង ខេត្តតាកែវ បញ្ជាក់ឱ្យឃើញថា៖ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ស្ថិតនៅចំណុចភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ពិតជាមានករណីធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច និងបក្ខពួកពីរនាក់ទៀតពុំស្គាល់ឈ្មោះដោយបាននាំគ្នាធ្វើសកម្មភាព



Scanned with CamScanner

យកដុំថ្មគប់ទៅលើកញ្ចក់រថយន្តរបស់ជនរងគ្រោះឈ្មោះ [redacted] ពៅ បណ្តាលឱ្យបែកកញ្ចក់រថយន្ត និងបណ្តាលឱ្យជនរងគ្រោះមានរបួសប្រាកដមែន។

៣-យល់ឃើញថា៖ អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted]រ៉ា ហៅ តូច និងបក្ខពួក ដែលបាននាំគ្នាជិះម៉ូតូហើយកាន់ដុំថ្មគប់ទៅលើកញ្ចក់ឡានរបស់ជនរងគ្រោះបណ្តាលឱ្យបែក និងមានរបួសដល់ជនរងគ្រោះឈ្មោះ [redacted] ពៅ ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ និងមានរបួសរបស់អ្នកដទៃទៀតផង ហើយអំពើនេះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសស្នាមដល់អ្នកដទៃ** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៤១៤ នៃក្រមព្រហ្មទណ្ឌ។

៤-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៦) គឺជាអនីតិជនក៏ពិតមែន ក៏ប៉ុន្តែជននេះមានស្មារតីយល់ដឹងអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែល ខ្លួនបានប្រព្រឹត្ត។

៥-យល់ឃើញថា៖ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៦) ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសស្នាមដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៤១៤ នៃក្រមព្រហ្មទណ្ឌ។

៦-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្ករបួសស្នាមដល់អ្នកដទៃ** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៤១៤ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថា៖ ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់គប្បីសម្រេចតាមការប្តឹងសុំ។

៧-តាមសេចក្តីសន្និដ្ឋានការពាររបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច ដោយសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយសំអាងថាកូនក្តីខ្លួនមានការភ្ញាក់រឭក ឆ្លើយសារភាពចំពោះតុលាការ និងមានការសោកស្តាយចំពោះអំពើដែលខ្លួនបានប្រព្រឹត្តផងដែរ។ តុលាការយល់ឃើញថា៖ ការស្នើសុំនេះមានមូលដ្ឋាន និងមានហេតុផលសមរម្យ។ ហេតុនេះគប្បីតុលាការសម្រេចពិចារណាសម្រេចតាមច្បាប់។

៨-យល់ឃើញថា៖ នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តូច បានឆ្លើយសារភាពចំពោះអំពើដែលពួកខ្លួនបានប្រព្រឹត្ត ហើយម្យ៉ាងឃើញថាជនជាប់ចោទនេះមានការសិក្សា និងរៀនសូត្របានតិចតួច ខ្វះការពិចារណាគ្រប់គ្រាន់ ម្យ៉ាងទៀតឃើញថាជនជាប់ចោទរូបនេះនៅជាអនីតិជននៅឡើយ បើគិតមកដល់ថ្ងៃកើតហេតុ គឺថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ នេះ។ ហេតុនេះ



Scanned with CamScanner

គប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើជននេះកំណត់ចំនួន **០៣ (បី) ឆ្នាំ** ស្របតាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៩-យល់ឃើញថា៖ ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ពៅ** បានប្តឹងទាមទារទាបទារសំណងការខូចខាតពីជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** សរុបមានចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ក៏ប៉ុន្តែឃើញថាដើមបណ្តឹងពុំបានដាក់ភស្តុតាងជូនតុលាការពិនិត្យឱ្យឃើញអំពីទំហំនៃការខូចខាតរបស់ខ្លួនជាក់លាក់នោះទេ។ ហេតុនេះគប្បីតុលាការពិចារណា និងសម្រេចអំពីសំណងនេះ។

១០-យល់ឃើញថា៖ វត្ថុតាងមានម៉ូតូ ០១គ្រឿងម៉ាកហុងដា C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ ពាក់ស្លាកលេខ៖ ភ្នំពេញ 1JD-5543 ត្រូវបានចៅក្រមស៊ើបសួរសម្រេចប្រគល់ឱ្យទៅឈ្មោះ [redacted] **យឿន** ភេទប្រុស អាយុ៥៨ឆ្នាំ តាមដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញលេខ៖ ២៧៨២/២០២៣ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ រួចហើយ។ ហេតុនេះតុលាការនឹងពិចារណាអំពីវត្ថុតាងនេះទៀតនោះទេ។

១១-យល់ឃើញថា៖ វត្ថុតាងរួមមានម៉ូតូ ០១គ្រឿងម៉ាកហុងដា C125 ពណ៌ខ្មៅពាក់ស្លាកលេខ៖ តាកែវ 1D-3266 និងទូរស័ព្ទដៃ ០១គ្រឿងម៉ាក VIVO ពណ៌ទឹកប៊ិច ជារបស់ឈ្មោះ [redacted] **កែវ** ក៏ប៉ុន្តែឃើញថាឈ្មោះ [redacted] **កែវ** ពុំមានជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើនេះនោះទេ។ ហេតុនេះគប្បីតុលាការសម្រេចប្រគល់វត្ថុចាប់យកនេះឱ្យទៅម្ចាស់ដើមវិញតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១២-យល់ឃើញថា៖ វត្ថុតាងរួមមានទូរស័ព្ទដៃមួយគ្រឿងម៉ាក IPHONE 6PLUS ពណ៌ទឹកប្រាក់ ០១គ្រឿង, កាំភ្លើងស្នប់ចំនួន ០១ និងគ្រាប់កង់ចំនួន ០៣ (នៅក្នុងកាំភ្លើងស្នប់) ជាវត្ថុតាងដែលជនជាប់ចោទបានយកទៅប្រព្រឹត្តបទល្មើស និងជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើ គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទលើឈ្មោះ [redacted] **រ៉ា ហៅ តូច** ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ ២០០៦) (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៣ (បី) ឆ្នាំ** ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការបង្កប្លួសស្លាមដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រៃញឹក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៤១៤ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **រ៉ា ហៅ តូច** ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៦) សងសំណងការខូចខាតឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ពៅ** ភេទប្រុស អាយុ៣៩ឆ្នាំ សរុបចំនួន **១០.០០០.០០០ (ដប់លាន) រៀល** ការទាមទារលើសពីនេះត្រូវច្រានចោល។

៣-ប្រគល់ម៉ូតូ ០១គ្រឿងម៉ាកហុងដា C125 ពណ៌ខ្មៅពាក់ស្លាកលេខ៖ តាកែវ 1D-3266 និងទូរស័ព្ទដៃ ០១គ្រឿងម៉ាក VIVO ពណ៌ទឹកប៊ិច ឱ្យទៅឈ្មោះ [redacted] **កែវ** ភេទប្រុស អាយុ១៩ឆ្នាំ វិញ។



Scanned with CamScanner

៤-វត្ថុតាងរួមមានទូរស័ព្ទដៃមួយគ្រឿងម៉ាក IPHONE 6PLUS ពណ៌ទឹកប្រាក់ ០១គ្រឿង, កាំភ្លើងស្នប់ចំនួន ០១ និងគ្រាប់កង់ចំនួន ០៣ (នៅក្នុងកាំភ្លើងស្នប់) សម្រេចរឹបអូស។

-សាលក្រមនេះបានបើកសវនាការជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាអសាធារណៈនាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៅ តូច និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពៅ។

-ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

................................................................................................

**-សេចក្ដីនេះ៖** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រម ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជួយសហការអនុវត្តសាលក្រមនេះឱ្យបានសម្រេចកាលបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

**-សាលក្រមនេះ** បានចូលជាស្ថាពរគិតចាប់តាំងពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ ចំពោះអគ្គព្រះរាជអាជ្ញា, ព្រះរាជអាជ្ញា និងទណ្ឌិតឈ្មោះ [redacted] **ហៅតូច** តទៅ ពីព្រោះផុតរយៈពេលប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ហើយ៕

................................................................................................

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃព្រហស្បតិ៍ ៦កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

តាកែវ, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

តាកែវ, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner